សម្លេងខ្មែរនៅបរទេស

# កុំយកបញ្ហាបូរណភាពទឹកដីខ្មែរមកធ្វើជាលេសដើម្បីផ្តល់អំណាចដល់នរោត្តម-សីហនុនោះ !

ដោយលី-ឡៀប ★ ថ្ងៃទី២១ ឧសភា ២០០៥

សេចក្តីថ្លែងការណ៍របស់«គណៈកម្មាធិការព្រំដែនកម្ពុជានៅប្រទេសបារាំងនិងនៅលើពិភពលោក» បានចេញផ្សាយកាលពីថ្ងៃទី២០ឧសភាឆ្នាំ២០០៥ គឺចំនួនពីរថ្ងៃមុនមហាបាតុកម្មនៅ «ត្រូកាដេរ៉ូ» ទីក្រុងប៉ារីសប្រទេសបារាំង (ថ្ងៃទី២២ឧសភាឆ្នាំ២០០៥) បានជ្រុះបាត់នូវការទាមទាររបស់ខ្លួនយ៉ាងសំខាន់មួយ ពោលគឺការស្វះស្វែងរក«អំណាចគ្រប់ប្រភេទ»ឲ្យដល់នរោត្តម-សីហនុ ប្រធាននៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

នៅក្នុងចំណុចទាំង១០ខរបស់ខ្លួន គណៈកម្មាធិការបានបញ្ជាក់ឲ្យឃើញសាជាថ្មីម្តងទៀត នូវគោលជំហរដំបូងរបស់ខ្លួន ដែលតាំងពីពេលចាប់បដិសន្ធិកាលពីឆ្នាំ១៩៩៩មក នូវការទទូចសុំឲ្យលុបចោលសន្ធិសញ្ញានិងកិច្ចព្រមព្រៀង ដែលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាមបានធ្វើជាមួយគ្នា ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩១ ក្នុងពេលប្រទេសកម្ពុជាកំពុងស្ថិតនៅក្រោមការកាន់កាប់នៃកងទ័ពវៀបរយរបស់ប្រទេសវៀតណាម ដោយផ្អែកទៅតាមក្របខណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ ស្តីអំពីបញ្ហាកម្ពុជា ។

ការជំរុះចោលនូវការតវ៉ាទាមទារអំណាចឲ្យនរោត្តម-សីហនុ វាជាទង្វើដ៏ត្រឹមត្រូវណាស់ ដើម្បីចៀសវាងការពាក់ព័ន្ធប្រឡាក់ប្រឡូសនៅក្នុងរឿងនយោបាយផ្សេងៗ ។

គណៈកម្មាធិការព្រំដែនកម្ពុជាបានបង្កើតឡើង ពុំមែនដើម្បីបំរើទិសដៅនយោបាយប្រភេទណាមួយឡើយ ។ បើគេអាចប្រកាន់នូវតួនាទីត្រឹមតែជាក្រុមឯករាជ្យជាតិនិយមមួយ គិតគូរអំពីតែរឿងបូរណភាពទឹកដីជូនប្រទេសជាតិ នោះជាការល្អប្រសើរក្រៃលែង ។ ការដើរចេញហួសពីរង្វង់បរិវេណនៃកាតព្វកិច្ច និងការទទួលខុសត្រូវនេះ មុខជាធ្វើឲ្យទូកឃ្លេងឃ្លោងពុំខានឡើយ ។

ចំពោះមតិរបស់យើង ក្រោយពីបានអាន«ឯកសារ»ទាំងពីរច្បាប់របស់គណៈកម្មាធិការព្រំដែនកម្ពុជា ៖ មួយរបស់លោក ស៊ាន-ប៉េងសែ ធ្វើនៅថ្ងៃទី១ឧសភាឆ្នាំ២០០៥ និងសេចក្តីរាយការណ៍របស់លោក ឌី-ការ៉េត ចុះថ្ងៃទី១១ឧសភាឆ្នាំ២០០៥ វាធ្វើឲ្យយើងយល់ថា គណៈកម្មាធិការដ៏ជាទីសង្ឃឹមរបស់ខ្មែរជាយូរឆ្នាំកន្លងមកនេះ ក្នុងមួយពព្រិចភ្នែកសោះ ស្រាប់តែចេញពីស្រោម ហើយប្រែកាឡាខ្លួនទៅជា «ក្រុមសីហនុនិយម»យ៉ាងរំភើយទៅវិញ ។ ការមន្ទិលសង្ស័យស្រពិចស្រពិលរបស់យើងពីមុនមកទាំងប៉ុន្មាន ក៏បានត្រូវគេបន្ថែចកន្ទុយឲ្យឃើញ ។

ដូចយើងបាននិយាយរួចមកហើយដូច្នោះ នៅក្នុងប្រការរកដំណោះស្រាយបូរណភាពទឹកដីនេះ សីហនុពុំចាំបាច់ត្រូវការ«អំណាច»នោះទេ គាត់គ្រាន់តែបំពេញតួនាទីជា «ព្រះរាជតំណាង» ឲ្យពេញលេញទៅ ជាការត្រឹមត្រូវពេកណាស់ទៅហើយ ជាពិសេសការអនុវត្តន៍តាមមាត្រាទី៣នៃ«រាជក្រឹត្យ» លេខ ៖ នស/រកត/០៥០៥/១៩៣ ។

ក៏ប៉ុន្តែសីហនុគាត់មានពុតត្បុតយ៉ាងក្រាស់ឃ្មឹក ។ គាត់គ្មានសុឆន្ទៈអ្វីនឹងធ្វើអំពីបញ្ហាទឹកដីព្រះនគរនេះទេ ។ តាមពិតទៅ គាត់កំពុងតែលេងល្បែង«បិទពួន»ជាមួយហ៊ុន-សែនទេតើ ។ សូមអញ្ជើញតាមដានព្រឹត្តិការណ៍នេះចុះ ៖

★ ថ្ងៃទី១៣មេសា២០០៥, សីហនុចាប់ផ្តើមមុនដោយនិយាយថា មានជនរួមជាតិ«ខ្លះ?» បាន<អ៊ីមែល>និងផ្ញើសំបុត្រមកគាត់ សុំឲ្យគាត់ចាប់ផ្តើមធ្វើ«ព្រះរាជបូជនិយកិច្ចថ្មី»មួយទៀត ដើម្បីទាមទារយកបូរណភាពទឹកដីមកវិញ ដូចកាលគាត់ធ្វើព្រះរាជបូជនិយកិច្ចទាមទារឯករាជ្យពីបារាំងកាលពីឆ្នាំ១៩៥២-៥៣យ៉ាងដូច្នោះដែរ ។ តែនៅជាមួយគ្នានេះ គាត់អំអែដំអូញថា ៖ ជំនាន់នោះ គាត់មានវ័យក្មេងគាត់អាចធ្វើបាន ។ ឥឡូវនេះ គាត់មានអាយុ៨៣ឆ្នាំទៅហើយ ជាមនុស្សចាស់ជរាពិការខ្វិនខ្វង់ ហើយណាមួយគ្មានទាំង«រដ្ឋអំណាច»ទៀតផង «ខ្លួនខ្ញុំគ្មានអំណាចអ្វីទាំងអស់មិនខុសពីជាជនអត់ការធ្វើម្នាក់នៅភ្នំពេញនោះទេ» គាត់ពោល ។

នៅត្រង់កន្លែងនេះ, សីហនុគាត់ភ្លេចខ្លួនគាត់មិននិយាយថា នៅពេលគាត់កំពុងសោយរាជ្យ តើហេតុអ្វីបានជាគាត់មិនធ្វើទេ ។ ហើយការសុំចូល«រ៉ឺត្រែត»ជាលេសរបស់គាត់ ដើម្បីបើកផ្លូវឲ្យកូនគាត់បានឡើងសោយរាជ្យនោះឡើយ ។ ពោលគឺគាត់បានស្ម័គ្រចិត្តដោយខ្លួនឯង ដើម្បីដើរតួកំសត់ជា«ជនអត់ការធ្វើថ្នាក់ដឹលុច» ។ ជាមួយគ្នាផងដែរ សីហនុគាត់ស្រាប់តែចង់ប្រកួតប្រជែងជាមួយរាជរដ្ឋាភិបាល ដោយនិយាយថា ៖ ពួកប្រទេសដូចជាសៀម យួន និងលាវ មិនដែលយល់ព្រមតាមសំណើរបស់គាត់ ធ្វើការពិនិត្យមើលគំនូសព្រំសីមា (ដែនដីនិងដែនសមុទ្រ) ជាមួយស្រុករបស់ពួកគេ ដោយយកតាមផ្ទាំងផែនទីនៃសេនាធិការយោធាអាមេរិកាំង ដែលបានប្រើប្រាស់កាលពីឆ្នាំ១៩៦៣-១៩៦៩ ។ «ពួកប្រទេសជិតខាងទាំងបីហ្នឹង គាត់ចូលចិត្តភស្តុតាង ហើយនិងចូលចិត្តធ្វើការតែជាមួយឯ.ឧ.វ៉ា-គឹមហុង តំណាងផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា (នៃរាជាណាចក្រទី២) ប៉ុណ្ណោះ» គាត់ពោល ។ មួយថ្ងៃបន្ទាប់មក (ថ្ងៃទី១៤មេសា២០០៥) គាត់ក៏និយាយផ្តាំផ្ញើអំពីការស្លាប់របស់គាត់ ថាតើឲ្យគេត្រូវធ្វើដូចម្តេចចំពោះខ្មោចគាត់ ដូចជាដាក់ខ្មោចបែរទៅទិសណា ដាក់ត្រង់កន្លែងណា រួចដល់ក្រោយពេលបូជាហើយ តើយកធាតុទៅទុកនៅទីកន្លែងណាជាដើម ។ ស្តេចសីហមុនីជាកូនឃើញឪពុកយ៉ាងដូច្នេះ ក៏ខំសរសេរសំបុត្រទៅជួយសំរាលទុក្ខសោកគ្រាំគ្រា ។

★ ដោយអត់ទ្រាំមិនបាន ហ៊ុន-សែនក៏សរសេរសំបុត្រទៅស្តេចសីហមុនី (ថ្ងៃទី២០មេសា២០០៥) ថា ៖ បើឪពុកព្រះអង្គគាត់គិតថាគាត់អាចដោះស្រាយបញ្ហាព្រំដែនបាន ឲ្យគាត់ធ្វើលមើលទៅ ។ គឺឲ្យគាត់បង្កើតជាក្រុមប្រឹក្សាជាតិជាន់ខ្ពស់មួយទទួលបន្ទុកកិច្ចការព្រំដែន ដែលមានសមាសភាពដូចតទៅនេះ ៖

- តំណាងព្រះមហាក្សត្រ ០១រូប ជាប្រធាន
- តំណាងប្រធានព្រឹទ្ធសភា ០១រូប ជាអនុប្រធាន
- តំណាងប្រធានរដ្ឋសភា ០១រូប ជាអនុប្រធាន
- តំណាងប្រមុខរាជរដ្ឋាភិបាល ០១រូប ជាសមាជិក
- តំណាងនៃគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា ក្នុងមួយគណបក្ស ០១រូប ជាសមាជិក ។

បើយោងតាមសំបុត្រខាងលើនេះ តាមពិតគឺហ៊ុន-សែនទេតើ ដែលជាអ្នកបើក«ភ្លើងខៀវ»ឲ្យធ្វើ ពុំមែនស្តេចសីហមុនីនិងនរោត្តម-សីហនុឡើយ ។ បើតាមការសង្កេតរបស់យើង ពួកអ្នករំភើបញាប់ញ័រភាគច្រើនមានរួមទាំងពួកសមាជិកគណៈកម្មាធិការព្រំដែនកម្ពុជា និងពួកសីហនុនិយម ក៏ដូចគ្នានឹងពួកក្រុមប្រឆាំងដែរ ស្រាប់តែនាំគ្នាអ៊ឹងកងឈ្ងូឆរឲ្យត-

ម្លៃទៅលើតែ នរោត្តម-សីហនុ តែម្នាក់គត់ ។ សួរថា តើហេតុអ្វីបានជាយ៉ាងដូច្នេះទៅវិញ ?? ។

★ ទទួលបាន«ភ្លើងខៀវ»ពីហ៊ុន-សែនរួចជាស្រេច ស្តេចសីហមុនីក៏ឡើងយន្តហោះទៅរកជួបឪពុកនៅឯប៉េកាំង ក្នុងលេសថា ទៅសួរសុខទុក្ខ ។

ប៉ែកូនមេចោរ ! គ្រាន់តែស្តេចសីហមុនីបង្ហើបរឿងហ៊ុន-សែនយល់ព្រមភ្លាម សីហនុដើបព្រឺសលែងឈឺ «លែងចង់ស្លាប់ឬសមតែស្លាប់» ទៀតហើយ ។ «ខ្ញុំសូមសម្តេចនិងរាជរដ្ឋាភិបាលកម្ពុជាព្រះមេត្តាជ្រាបថា ព្រះករុណា ព្រះវររាជបិតា ព្រះនរោត្តម-សីហនុនៃកម្ពុជា ព្រះអង្គសព្វព្រះរាជហឫទ័យ ធ្វើជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ក្រោយដែលខ្ញុំបានពិគ្រោះផ្ទាល់ជាមួយព្រះអង្គនៅព្រឹកថ្ងៃទី២៨ខែមេសានេះ», ស្តេចសីហមុនីពោល «ព្រះករុណា ព្រះវររាជបិតានៃខ្ញុំ ព្រះអង្គនៅមានព្រះកាយពលគ្រប់គ្រាន់ ដើម្បីបំពេញភារកិច្ចនេះ ។ ព្រះអង្គទទួលខុសត្រូវផ្ទាល់ ហើយមិនបំពេញការងារនៅក្នុងការិយាល័យទេ គឺស្តេចយាងទៅដល់ទីកន្លែងតែម្តង ដើម្បីបំពេញការងារជាបងប្អូន ជាមួយនឹងរាជាណាចក្រថៃ សាធារណរដ្ឋសង្គមនិយមវៀតណាម នឹងសាធារណរដ្ឋប្រជាមានិតឡាវ បើប្រទេសទាំងបីនេះមិនយល់ទាស់ទេ», ស្តេចសីហមុនីពោលបញ្ជាក់បន្ថែម នៅក្នុងសំបុត្រមួយច្បាប់រាយការណ៍ប្រាប់ទៅហ៊ុន-សែនវិញ (ថ្ងៃទី២៥មេសា២០០៥) ។

មើលទៅឃើញថាដូចជាហាំហានមែនទែន ។ ក៏ប៉ុន្តែសូមកំភ្លេចថា អ្វីដែលហ៊ុន-សែនចង់ឲ្យស្តេចសីហមុនីនិងសីហនុធ្វើ គឺបានផលជាវិជ្ជមានសមតាមដូចចិត្តប្រាថ្នាខ្លួនមែន ។

★ ថ្ងៃទី២៧មេសា២០០៥, ដើម្បីជាការកែខ្លួន និងដើម្បីឲ្យគេជឿថាគាត់ពុំមែន«មនុស្សចាស់ឈឺជិតស្លាប់»ទេ សីហនុក៏ចេញសេចក្តីថ្លែងការណ៍មួយនិយាយរៀបចំអកឡុកលើយដាក់ទៅអ្នកកាសែតណាម្នាក់ (តាមពិតគឺគ្មានអ្នកកាសែតណាចង់ដឹង ឬក៏បន់ឲ្យគាត់ឆាប់ស្លាប់នោះទេ) ថា ៖ សុំទោសទៅចុះ ដែលជននេះចង់ឲ្យគាត់ស្លាប់នោះ គឺគាត់អត់ស្លាប់វិញទេ ហើយមិនត្រឹមប៉ុណ្ណឹងសោត គាត់កាន់តែមានសុខភាពល្អឡើងៗជាលំដាប់ ។ មានន័យថា ៖ គាត់មានកម្លាំងកំហែងអាចរែកពន់ការងារនេះកើត សុំតែប្រគល់កិច្ចការនោះមកឲ្យគាត់ចុះ ! ។

★ ឃើញដូច្នេះ ជា-ស៊ីមមុនគេ ក៏ឆ្លើយថា សូមព្រះអង្គទទួលតាមសព្វព្រះរាជហឫទ័យកូណាសេះ (សំបុត្រថ្ងៃទី២៦មេសា២០០៥) ។ ហ៊ុន-សែននិងរណឫទ្ធិ ក៏បន្ទរតាមក្រោយដូចខ្យងក្តក់តគ្នា ៖ សាធុៗ ! ។

★ ថ្ងៃទី២៧មេសា២០០៥, មួយថ្ងៃក្រោយមកប៉ុណ្ណោះ ពុំចាំបាច់មាន«រាជក្រឹត្យ»ត្រាស់តែងតាំងគាត់ឲ្យធ្វើជា«ព្រះរាជតំណាង»ស្អីទេ, ស្តេចចូលរ៉ុត្រែតរូបនេះ ក៏<ហ្វាក់>ទៅកុងស៊ុវ៉ាំង គង់-សំអុល ដូចរបៀបខ្លួនគាត់ពីកាលនៅសោយរាជ្យអីចឹងថា ឲ្យទូលព្រះសង្ឃនិងជំរាបទៅប្រជានុរាស្ត្រថា គាត់នឹងត្រឡប់ចូលស្រុក (ពីនិរទេសខ្លួនឯង) នៅថ្ងៃទី៨ឧសភា២០០៥ ជាមួយកូន ។ បើពួកអ្នកកាសែតណាចង់សួរអ្វី ឲ្យទៅជួបសួរនៅឯវាំងទៅ ។ រួចបន្ទាប់មក សុំកោះហៅសមាជិកទាំងអស់នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែនទាំងអស់ទៅប្រជុំ នៅដំណាក់សិរីមង្គល ក្រោមអធិបតីរបស់គាត់ នាថ្ងៃទី៩ឧសភា ។

សូមបញ្ជាក់ថា ថ្ងៃទី២៧មេសា២០០៥នេះ ក៏ជាថ្ងៃស្តេចសីហមុនីធ្វើ«រាជក្រឹត្យ» លេខ ៖ នស/រកត/០៥០៥/១៩៣ ដែលត្រាស់បង្គាប់បង្កើត«ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន» ក្នុងខណៈពេលដែលព្រះអង្គកំពុងគង់នៅទីក្រុងប៉េកាំងជាមួយឪពុកនៅឡើយ ។ យើងបានដឹងអំពីរឿងស្តេចសីហមនីធ្វើរាជក្រឹត្យនេះ ដោយសារសីហនុគាត់ទម្លាយការសម្ងាត់ឲ្យយើងដឹងនាថ្ងៃទី៥ឧសភា២០០៥ថា ស្តេចសីហមុនីនឹងឡាយព្រះហត្ថលេខាលើរាជក្រឹត្យនេះនាថ្ងៃទី៩ឧសភា២០០៥ ។ រឿងដែលសំខាន់នោះ សីហនុគាត់មិនបានថាស្អីទាំងអស់ អំពីរាជក្រឹត្យនេះទេ គឺគាត់ទុករហូតដល់វេលាល្ងាចចប់ប្រជុំទី១ថ្ងៃទី១១ឧសភា២០០៥ ។

មកដល់ថ្ងៃទី២ឧសភា២០០៥, សីហនុក៏ផ្លាស់ប្តូរចិត្តលែងទៅស្រុកខ្មែរ ហើយលើកអង្គប្រជុំមកធ្វើនៅវាំងឯក្រុងប៉េកាំងវិញ ដែលធ្វើសម-រង្ស៊ីខកខានលែងបានចូលស្រុកជាមួយគាត់ទៅ ។ ថ្ងៃប្រជុំដំបូងនឹងធ្វើចាប់ពីម៉ោង៨ព្រឹក នាថ្ងៃទី១១ឧសភាឆ្នាំ២០០៥ ។

★ ថ្ងៃទី៥ឧសភា២០០៥, ក្រៅអំពីនិយាយបន្តេចប្រាប់គេឲ្យបានដឹងថា ស្តេចសីហមុនីនឹងឡាយព្រះហត្ថលេខាលើ «រាជក្រឹត្យ» លេខ ៖ នស/រកត/០៥០៥/១៩៣, សីហនុថែមទាំងបញ្ជាក់ថា កិច្ចការនៅក្នុងអង្គប្រជុំត្រូវរក្សាជា«ការសម្ងាត់» ដូចដែលមានចែងនៅក្នុងរាជក្រឹត្យស្រាប់ ។

★ ថ្ងៃទី១១ឧសភាឆ្នាំ២០០៥, ក្នុងសារមួយទៅកាន់ប្រជាជាតិ, សីហនុហាក់ដូចជាចង់ប្រាប់ឲ្យដឹងអំពី«បរាជ័យ»នៃកិច្ចប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។ ចំណុចទី១- គាត់និយាយថា រាជក្រឹត្យដែលធ្វើឡើងកាលពីថ្ងៃទី២៧ខែមេសាឆ្នាំ២០០៥ ដែលបានឡាយព្រះហត្ថលេខាដោយស្តេចសីហមុនីនោះ គឺជាការ«តាក់តែងឡើងគ្រប់លក្ខណៈដោយរាជរដ្ឋាភិបាល» ។ មានន័យថា កូនគាត់ដែលស្ថិតនៅជាមួយគាត់ឯក្រុងប៉េកាំងដែរ កាលពីថ្ងៃទី២៧មេសា២០០៥នោះ ពុំមែនជាអ្នកតាក់តែងគ្រប់លក្ខណៈនៃរាជក្រឹត្យនេះទេ ។ មានន័យម្យ៉ាងទៀតថា អ្នកដែលផ្តើមគំនិតបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែននេះ និងដែលមានការតែងតាំងគាត់ឲ្យធ្វើជា«ព្រះរាជតំណាង» ឬឲ្យធ្វើជា«ប្រធានក្រុមប្រឹក្សា» គឺជាគំនិតដើមរបស់រាជរដ្ឋាភិបាល ពោលប្រហែលសំដៅទៅលើហ៊ុន-សែន ។ ដូច្នេះកិត្តិយសនេះត្រូវបានទៅហ៊ុន-សែន ពុំមែនជារបស់ឪពុកកូនសីហនុទេ ។ ចំណុចទី២- សីហនុពោលបញ្ជាក់ថា រាជក្រឹត្យដែលកូនគាត់ធ្វើតាមពាក្យបង្គាប់បញ្ជារបស់រាជរដ្ឋាភិបាលនោះ ពុំបានផ្តល់នូវអំណាចអ្វីដល់សីហនុឲ្យសំរេចកិច្ចការណាមួយទេ ។ មានន័យថា ៖ រាជរដ្ឋាភិបាលបានបង្គាប់ទៅស្តេចសីហមុនីកុំផ្តល់អំណាចទៅឪពុក ។ សីហនុតបថា ៖ បើឯងចិត្តសៀងឲ្យអំណាចអញមក !

★ ក្រោយបរាជ័យប្រជុំថ្ងៃទី១១ឧសភាឆ្នាំ២០០៥, បញ្ហាការផ្តល់អំណាចដល់សីហនុ បានក្លាយជាចំណុចសំខាន់ជាងបញ្ហាព្រំដែន ។

យើងសូមងាកត្រឡប់ទៅថ្ងៃទី១ឧសភាឆ្នាំ២០០៥វិញ ដែលជាថ្ងៃលោកស៊ាន-ប៉េងសែ ធ្វើការតវ៉ាទាមទារឲ្យរដ្ឋសភានិងព្រឹទ្ធសភា បង្កើតច្បាប់មួយ ផ្តល់ «អំណាចគ្រប់ប្រភេទ» ដល់សីហនុ ។ ដល់មកដល់ថ្ងៃទី១១ឧសភាឆ្នាំ២០០៥ គ្រប់គ្នារួមទាំងសីហនុ, លោកឌី-កាវ៉េត, លោកសម-រង្ស៊ី, ម្ចាស់ក្សត្រីវជរ៉ា និងមនុស្សមួយចំនួនទៀត ក៏យល់ស្របដូចគ្នា ថាគេត្រូវរកអំណាចឲ្យសីហនុជាមុនសិន ទើបអាចដោះស្រាយបញ្ហាព្រំដែនចេញ ។

មកដល់ចំណុចនេះ យើងបានធ្វើសំនួរយ៉ាងច្រើនរួចមកហើយ អំពីកំហុសនៃការផ្តល់អំណាចទៅឲ្យសីហនុ ដែលជាស្តេចចូលរ៉ុត្រែតនិងមានតួនាទីត្រឹមតែជា«ព្រះរាជតំណាង» ។ មាត្រាទី៧នៃរដ្ឋធម្មនុញ្ញ ពុំបានផ្តល់អំណាចអ្វីដល់ព្រះមហាក្សត្រទេ ។ សួរថាតើហេតុអ្វីបានជាគេត្រឡប់ជានាំគ្នាតវ៉ារក«អំណាចគ្រប់ប្រភេទ»ឲ្យសីហនុទៅវិញ ? ។ ម៉្យាងទៀត បើគេយល់ថាហ៊ុន-សែនជាអ្នកបង្គាប់ព្រះមហាក្សត្រឲ្យធ្វើរាជក្រឹត្យ ចុះហេតុអ្វីក៏មិននាំគ្នាទៅសុំរំលែកអំណាចពីហ៊ុន-សែនឲ្យសីហនុតែម្តងទៅ ។ បើមិនបាន«គ្រប់ប្រភេទ»ទេ ក៏បានខ្លះៗដែរ ។ គិតទៅបញ្ហាព្រំដែនស្រុកយើង វាមកចប់ត្រឹមអំណាចរបស់សីហនុហ្នឹងសោះ (!!) ។៚